**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ............................... ក.ប/ស.ជ.ណ.អ.ធ.ក

# សេចក្តីជូនដំណឹង
# ស្តីពី
# ការពន្យារពេលការធ្វើស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងខែមិថុនា រហូតដល់សប្តាហ៍ទី២ នៃខែកក្កដា ឆ្នាំ២០២៥

យោងប្រកាសលេខ៣៥៨/២១ ក.ប/ប្រ.ក.អ.ធ.ក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការដាក់ឱ្យដំណើរការរបបស្វ័យប្រកាសអធិការកិច្ចការងារ និងការធ្វើអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម និងសេចក្តីជូនដំណឹងលេខ០១៨/២៥ ក.ប/ស.ជ.ណ.អ.ធ.ក ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២៥ ស្តីពីកាតព្វកិច្ចអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្មក្នុងខែមិថុនា ឆ្នាំ២០២៥ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន ដែលស្ថិតក្នុងដែនអនុវត្តនៃច្បាប់ស្តីពីការងារឱ្យបានជ្រាបថា លោក/លោកស្រី មានកាតព្វកិច្ចធ្វើស្វ័យប្រកាសអធិការកិច្ចការងារក្នុងប្រព័ន្ធស្វ័យប្រវត្តិកម្មចំនួន ២ (ពីរ) លើកក្នុងមួយឆ្នាំ គឺលើកទី១ នៅក្នុងខែមិថុនា និងលើកទី២ នៅក្នុងខែធ្នូ នៃឆ្នាំនីមួយៗ តាមរយៈគេហទំព័រ https://sicms.mlvt.gov.kh ។

ដោយសង្កេតឃើញថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានមួយចំនួនមិនទាន់បានបញ្ចប់ការបំពេញរបាយការណ៍ស្វ័យប្រកាសអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (SICMS) ក្រសួងនឹងពន្យារពេលការធ្វើស្វ័យប្រកាសអធិការកិច្ចការងារនេះ រហូតដល់សប្តាហ៍ទី២ នៃខែកក្កដា (ត្រឹមថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២៥) ដើម្បីសម្រួល និងលើកទឹកចិត្តដល់ការអនុវត្តកាតព្វកិច្ចនេះ ឱ្យបានពេញលេញ។

ក្នុងករណីខកខាន ឬមិនបានអនុវត្តកាតព្វកិច្ចធ្វើស្វ័យប្រកាសអធិការកិច្ចការងារតាមកាលកំណត់ខាងលើ ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានសាមីត្រូវទទួលរងការផាកពិន័យ និងចំណាត់ការពីអធិការការងារស្របតាមច្បាប់ជាធរមាន។

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សង្ឃឹមយ៉ាងមុតមាំថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងអស់អនុវត្តបានត្រឹមត្រូវតាមសេចក្តីជូនដំណឹងនេះ ប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ............ ខែ ............ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ..... ខែ ....... ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ